**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក**

សេចក្តីប្រកាសព័ត៌មាន

# "កម្ពុជា និងឥណ្ឌា នឹងជំរុញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ល្អប្រសើរឱ្យកាន់តែស៊ីជម្រៅ"

ឯកឧត្តម សុខ ចិន្តាសោភា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជំនួបសម្តែងការគួរសមពី **លោកជំទាវបណ្ឌិត ដេវីយ៉ានី អ៊ុតាំ ខូប្រាហ្គេត** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួង នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣។

ភាគីទាំងពីរ បានសម្តែងនូវការពេញចិត្តចំពោះវឌ្ឍនភាពនៃទំនាក់ទំនងល្អប្រសើរ នៃមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងប្រទេសទាំងពីរជាច្រើនឆ្នាំមកនេះ ហើយបានប្តេជ្ញារួមគ្នាក្នុងការធ្វើឱ្យប្រសើរឡើងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការលើវិស័យនានា ដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក រួមមាន នយោបាយ ពាណិជ្ជកម្ម វិនិយោគ វប្បធម៌ ការពារជាតិ ទេសចរណ៍ និងការតភ្ជាប់រវាងប្រជាជន និងប្រជាជន។ ភាគីទាំងពីរបានរំលឹកដោយក្តីសោមនស្ស និងបានចាត់ទុកព្រះរាជទស្សនកិច្ចផ្លូវរដ្ឋរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងទស្សនកិច្ចផ្លូវការរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ក្នុងតួនាទីជាអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោកកម្ពុជា នៅសាធារណរដ្ឋឥណ្ឌា កាលពីដើមឆ្នាំនេះ គឺជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ ដើម្បីធ្វើឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតនូវទំនាក់ទំនងដ៏ប្រសើររវាងប្រទេសទាំងពីរ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះការចូលរួមចំណែករបស់ឥណ្ឌា ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា ទន្ទឹមនឹងនេះ **លោកជំទាវឯកអគ្គរដ្ឋទូត** បានបញ្ជាក់សាជាថ្មីអំពីការប្តេជ្ញារបស់រដ្ឋាភិបាលឥណ្ឌា ក្នុងការគាំទ្រកម្ពុជាដើម្បីពន្លឿនការអភិវឌ្ឍជាតិ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ភាគីទាំងពីរ បានកត់សម្គាល់ដោយក្តីរីករាយចំពោះភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ និងបានលើកទឹកចិត្តឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធពិភាក្សាបន្ថែមអំពីមធ្យោបាយថ្មីៗ ដើម្បីបំពេញបន្ថែមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការដែលមានស្រាប់ ដែលមានគោលបំណងពង្រីកការវិនិយោគ និងពាណិជ្ជកម្មទ្វេភាគី។ ភាគីទាំងពីរបានសង្កត់ធ្ងន់ពីសារៈសំខាន់នៃកិច្ចប្រជុំគណៈកម្មការចម្រុះលើកទី៣ រវាងក្រសួងការបរទេសទាំងពីរ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងញូវដែលី នាពេលឆាប់ៗខាងមុខ ដែលកិច្ចប្រជុំនេះជាយន្តការសំខាន់សម្រាប់ពិនិត្យឡើងវិញនូវកិច្ចសហការដែលកំពុងមាន ស្វែងរកកិច្ចសហប្រតិបត្តិការលើវិស័យថ្មីៗ និងកំណត់ទិសដៅសកម្មភាពថ្មីផ្សេងទៀត ដើម្បីពង្រឹង និងពង្រីកភាពជាដៃគូនៃប្រទេសទាំងពីរ។ ភាគីទាំងពីរ បានស្វាគមន៍ចំពោះការធ្វើការរួមគ្នាបន្ថែមទៀត ក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា រវាងប្រទេសទាំងពីរ ដែលនឹងផ្តល់ប្រយោជន៍យ៉ាងធំធេងក្នុងការអភិវឌ្ឍឌីជីថល នៅកម្ពុជា។

ភាគីទាំងពីរ ក៏បានផ្លាស់ប្តូរយោបល់លើបញ្ហាតំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍ និងកង្វល់រួម ព្រមទាំងបានឯកភាពគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌពហុភាគីផងដែរ៕

ថ្ងៃសុក្រ ១៣កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០២៣